**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
លេខ...០៧១........បទ.ស.ស.រ........

# សេចក្ដីសម្រេច
# ស្ដីពី
# ការកែសម្រួលសមាសភាព
# នៃក្រុមការងារនីតិកម្មនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្ដីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០១៤ ស្ដីពីរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការងារចាំបាច់របស់ក្រសួង។

## សម្រេច

**ប្រការ១ .-**

កែសម្រួលសមាសភាព ក្រុមការងារនីតិកម្មនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សាវ៉ាត់ ខាន់** | រដ្ឋលេខាធិការ | ប្រធាន |
| ២- | ឯកឧត្តម **ភាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការ | អនុប្រធានទី១ |
| ៣- | ឯកឧត្តម **ខាយ ឃុនហេង** | រដ្ឋលេខាធិការ | អនុប្រធានទី២ |
| ៤- | ឯកឧត្តម **ម៉ុង ចរិយា** | ប្រធានបញ្ញត្តិករទូរគមនាគមន៍កម្ពុជា | សមាជិក |

| | | | |
|---|---|---|---|
| ៥- | ឯកឧត្តម **ភុយ ពុំ** | អនុរដ្ឋលេខាធិការ | សមាជិកអចិន្ត្រៃយ៍ |
| ៦- | ឯកឧត្តម **មាស ប៉ូ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧- | ឯកឧត្តម **ចាយ ណារិទ្ធ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨- | ឯកឧត្តម **ខូវ មករា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩- | លោកជំទាវ **ម៉ី តឿន** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ១០- | ឯកឧត្តម **គង់ សេង** | សមាជិកទី១ នៃ ប.ក.ទ.ក. | សមាជិក |
| ១១- | ឯកឧត្តម **សុខ ឡេង** | ប្រធានលេខាធិការដ្ឋាននៃ ប.ក.ទ.ក. | លេខាធិការ |
| ១២- | ឯកឧត្តម **អោក ប៉ូរ៉ា** | អគ្គនាយកប្រៃសណីយ៍កម្ពុជា | សមាជិក |
| ១៣- | ឯកឧត្តម **តុល ញ៉ាក់** | អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៤- | ឯកឧត្តម **ជា មានិត** | អគ្គនាយកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | សមាជិក |
| ១៥- | លោក **ឡាយ តួក** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៦- | លោក **ម៉ែន ធីន** | អនុប្រធានអង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា | លេខាកត់ត្រា |

**ប្រការ២ .-**

ក្រុមការងារនីតិកម្មមានភារកិច្ចដូចតទៅ ៖

- លើកគម្រោងកសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានសម្រាប់បម្រើឱ្យវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើវិសោធនកម្មគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានដែលកំពុងអនុវត្តជាធរមានក្នុងករណីចាំបាច់
- ពិនិត្យ ឆ្លងសេចក្តីព្រាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានដែលទាក់ទងនឹងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មុននឹងដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីពិនិត្យសម្រេច។ ឯកឧត្តម និងលោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការដែលទទួលបន្ទុកការងារតាមសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និងទូរគមនាគន៍ មានភារកិច្ចដឹកនាំការរៀបចំសេចក្តីព្រាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានដោយផ្អែកលើមូលដ្ឋានគម្រោងរៀបចំលិខិតបទដ្ឋានគតិយុត្តិបច្ចុប្បន្នកម្មរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់ឆ្នាំ២០១៤-២០១៨ និងការចាំបាច់ដទៃទៀត ដោយពិភាក្សាឱ្យបានឯកភាពគ្នាជាមុន មុននឹងដាក់ជូនក្រុមការងារនីតិកម្ម
- ពិនិត្យផ្តល់យោបល់ជូនឯកឧត្តមរដ្ឋមន្ត្រីពិនិត្យសម្រេចពាក់ព័ន្ធទៅនឹងទិដ្ឋភាពគតិយុត្តិ នូវរាល់ឯកសារ សំណើ កិច្ចព្រមព្រៀង កិច្ចសន្យា និងអាជ្ញាបណ្ណទាំងឡាយដែលទាក់ទងនឹងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ចាត់ចែងធ្វើសេចក្តីព្រាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានដែលឯកឧត្តមរដ្ឋមន្ត្រីបានសម្រេចរួចហើយទៅស្ថាប័នមានសមត្ថកិច្ចតាមនីតិវិធីជាធរមាន
- ផ្សព្វផ្សាយ និងតាមដានការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន
- ធ្វើរបាយការណ៍តាមកាលកំណត់ស្តីពីសកម្មភាពការងារជូនឯកឧត្តមរដ្ឋមន្ត្រី។

**ប្រការ៣ ..**

អនុប្រធាន និងសមាជិកនៃក្រុមការងារនីតិកម្មត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចអញ្ជើញអ្នកមានសមត្ថកិច្ចផ្សេងៗទៀតនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យចូលរួមកិច្ចប្រជុំបំភ្លឺការងារ ឬសិក្សាលើឯកសារពាក់ព័ន្ធក្នុងករណីចាំបាច់។

**ប្រការ៤ ..**

សេចក្តីសម្រេចលេខ ១៣៤ បទ.សសរ ចុះថ្ងៃទី២៨ខែតុលាឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារនីតិកម្មរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ..**

ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកដ្ឋានបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន អគ្គាធិការដ្ឋាន វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង មន្ទីរ អង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

**កន្លែងទទួល ៖**

- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង
- ដូចប្រការ៥ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ